អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១២

សេចក្ដីប្រកាសព័ត៌មាន

សន្និសីទស្ដីពីទស្សនវិស័យចម្រុះអំពីកេរដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ត្រូវបានបញ្ចប់

សន្និសីទថ្នាក់ខ្ពស់ស្ដីពីកេរដំណែលនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដែលរៀបចំរួមគ្នាដោយ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) និង គណៈកម្មការប្រព្រឹត្តកម្មនៃអង្គការ-សមាគមការពារសិទ្ធិមនុស្សកម្ពុជា (CHRAC) ត្រូវបានបញ្ចប់ថ្ងៃនេះ បន្ទាប់ពីមានការពិភាក្សាយ៉ាងផុសផុលរយៈពេលពីរថ្ងៃ។

នៅក្នុងអំឡុងពេលពីរថ្ងៃនៃសន្និសីទ កិច្ចពិភាក្សាធំៗចំនួន៤និងក្រុមពិភាក្សាចំនួន៦ ត្រូវបានរៀបចំឡើង ដែលចូលរួមដោយវាគ្មិនជាតិនិងអន្តរជាតិចំនួន ៦០នាក់ និងសាធារណជនចំនួនជាង ២០០នាក់ ក្នុងនោះរួមមាន ចៅក្រមនិងមន្ត្រីច្បាប់មកពី អ.វ.ត.ក អ្នកជំនាញច្បាប់អន្តរជាតិ សាស្ត្រាចារ្យច្បាប់ និងសមាជិកអង្គការក្រៅរដ្ឋាភិបាល បានពិភាក្សានិងផ្លាស់ប្ដូរយោបល់គ្នាទៅលើប្រធានបទជាច្រើនទាក់ទងនឹងកេរដំណែលនៃ អ.វ.ត.ក ក្នុងនោះរួមមាន កេរដំណែលច្បាប់និងកេរដំណែលសង្គម កេរដំណែលចិត្តសាស្ត្រ បទពិសោធន៍និងមេរៀននានាដែលទទួលបានពីការងាររបស់ អ.វ.ត.ក ក៏ដូចជាពីតុលាការឧក្រិដ្ឋកម្មអន្តរជាតិដទៃទៀត។

អង្គសន្និសីទត្រូវបានបញ្ចប់ដោយការផ្ដល់អនុសាសន៍ជាច្រើនដើម្បីរក្សាកេរដំណែលរបស់ អ.វ.ត.ក ឲ្យច្រើនបំផុតតាមដែលអាចធ្វើទៅបាន។ សម្រាប់រយៈពេលខ្លី អ.វ.ត.ក ត្រូវតែទទួលបានជំនួយថវិកាគ្រប់គ្រាន់ដើម្បីអាចបន្តបេសកកម្មដ៏សំខាន់របស់ខ្លួនបាន។ សម្រាប់រយៈពេលវែង អ.វ.ត.ក គួរតែធ្វើឲ្យកាន់តែប្រសើរថែមទៀត និងភ្ជាប់ទំនាក់ទំនងរបស់ខ្លួនជាមួយប្រព័ន្ធតុលាការជាតិ ដើម្បីចែករំលែកចំណេះដឹងនិងជំនាញ ព្រមទាំងដំណើរការនីតិវិធីរបស់តុលាការនិងការគ្រប់គ្រងប្រព័ន្ធរដ្ឋបាលតុលាការ។ កេរដំណែលសំខាន់ៗមួយចំនួនដែលគួរឲ្យកត់សម្គាល់ និងដែលត្រូវបានទទួលស្គាល់ទូទាំងពិភពលោក គឺតួនាទីរបស់ជនរងគ្រោះក្នុងនាមជាដើមបណ្ដឹងរដ្ឋប្បវេណីនៅក្នុងដំណើរការនីតិវិធី សន្ទុះនៃការគាំទ្រនិងចូលរួមរបស់សាធារណជនដែលមិនធ្លាប់មានពីមុនមកនៅតុលាការណាមួយនៅលើពិភពលោក និងសារដ៏សំខាន់មួយគឺ "ពុំមានជនណាម្នាក់អាចគេចរួចពីការទទួលខុសត្រូវនៅចំពោះមុខច្បាប់ចំពោះបទឧក្រិដ្ឋធ្ងន់ធ្ងរដែលបានខ្លួនប្រព្រឹត្តឡើយ មិនថាទោះជា ៤០ ឆ្នាំកន្លងផុតទៅហើយក្ដី"។

កេរដំណែលរបស់ អ.វ.ត.ក មិនត្រឹមតែជាអ្វីដែលបានកើតឡើងនៅក្នុងបន្ទប់សវនាការប៉ុណ្ណោះទេ ក៏ប៉ុន្តែគឺជាការចូលរួមចំណែករបស់បុគ្គលគ្រប់រូប និងអង្គការដៃគូនានា នៅក្នុងដំណើរការរបស់ អ.វ.ត.ក ក៏ដូចជានៅក្នុងសកម្មភាពនានាពាក់ព័ន្ធនឹង អ.វ.ត.ក ហើយដែលអ្នកទាំងនោះបានចូលរួមនៅក្នុងសន្និសីទនេះដែរ។ កិច្ចខិតខំ

ប្រឹងប្រែងមួយចំនួនបានក្លាយជាកេរដំណែលដ៏ជាក់ស្តែងរួចទៅហើយ ដូចជា គម្រោងសាលាក្តីទូរនិម្មិត និងមជ្ឈមណ្ឌលឯកសាររបស់ អ.វ.ត.ក ជាដើម។

អ្នករៀបចំសន្និសីទនឹងចងក្រងរាល់កិច្ចពិភាក្សានិងអនុសាសន៍ទាំងអស់នៅក្នុងសន្និសីទនេះ និងរៀបចំជាឯកសាររបាយការណ៍មួយ ហើយរបាយការណ៍នោះនឹងត្រូវចែកជូនសាធារណជន ជាការចែករំលែកចំណេះដឹងនិងបទពិសោធន៍នៃសន្និសីទនេះ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

លោក នេត្រ ភក្ត្រា
មន្ត្រីនាំពាក្យ អ.វ.ត.ក
ទូរស័ព្ទដៃ: +៨៥៥ (០)១២ ៤៨៨ ១៥៦
សារអេឡិចត្រូនិក: neth.pheaktra@eccc.gov.kh

លោក សួន ប៊ុនស័ក្ត
អគ្គលេខាធិការ CHRAC
ទូរស័ព្ទដៃ: +៨៥៥ (០)៩២ ៣៤៤ ៣៥៧
សារអេឡិចត្រូនិក: suonbunsak@yahoo.com